**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ការរៀបចំកម្មវិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី១៣០ ទិវាពលកម្មអន្តរជាតិ ១ ឧសភា ឆ្នាំ២០១៦

ដើម្បីអបអរសាទរខួបអនុស្សាវរីយ៍លើកទី១៣០ ទិវាពលកម្មអន្តរជាតិ ១ ឧសភា ឆ្នាំ២០១៦ ក្រោមប្រធានបទ "លើកកម្ពស់សេរីភាព អង្គការវិជ្ជាជីវៈ និងស្ថិរភាពផលិតកម្ម ដើម្បីបង្កើនផលិតភាព និងការងារ" ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងរៀបចំនូវវេទិកាពិភាក្សាអំពីទំនាក់ទំនងវិជ្ជាជីវៈនៅកម្ពុជា ដោយមានការចូលរួមយ៉ាងទូលំទូលាយពីគ្រប់តំណាងភាគីពាក់ព័ន្ធក្នុងវិស័យការងារដូចជា តំណាងក្រសួង-ស្ថាប័នរដ្ឋពាក់ព័ន្ធ អង្គការវិជ្ជាជីវៈ កម្មករនិយោជិត និយោជក អង្គការអន្តរជាតិខាងការងារ (ILO) និងអង្គការសង្គមស៊ីវិល ដើម្បីពិភាក្សាស្វែងរកដំណោះស្រាយរួមគ្នាលើបញ្ហាកង្វល់ ឬសំណូមពរជាអាទិភាពរបស់បងប្អូនកម្មករនិយោជិត និងនិយោជក។ ទន្ទឹមនឹងនេះ ដើម្បីបង្កើតឱកាសសប្បាយរីករាយដល់បងប្អូនកម្មករនិយោជិត ដែលកំពុងបម្រើការងារក្នុងវិស័យឧស្សាហកម្មផ្នែកវាយនភណ្ឌ កាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើង ក្រសួងក៏បានសហការជាមួយសមាគមរោងចក្រកាត់ដេរនៅកម្ពុជា(GMAC) ស្ថានីយទូរទស្សន៍PNN អង្គការវិជ្ជាជីវៈ និងដៃគូពាក់ព័ន្ធនានា រៀបចំ "**កម្មវិធីសម្រស់ឯកវាយនភណ្ឌឆ្នាំ២០១៦**" នៅថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៦ ផងដែរ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម សាធារណជន កម្មករនិយោជិត អង្គការវិជ្ជាជីវៈ និយោជក អង្គការជាតិនិងអន្តរជាតិ មេត្តាជ្រាបជាព័ត៌មាន។

*រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ២០១៦*

*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩*

Scanned by CamScanner